## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍    ...ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

លេខ: ១១៤១........ប្រក.បទ.សហវ.ចមព

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់ប្រាក់ឧបត្ថមសម្រាប់
## ក្រុមការងារត្រួតពិនិត្យនិងការងារគ្រប់គ្រង

## ទេសរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍។
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។/.

- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- បានឃើញអនុក្រឹត្យលេខ 0៤ អនក្រ.បក ចុះថ្ងៃទី២0 ខែមករា ឆ្នាំ២000 ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ។
- បានឃើញប្រកាសលេខ 00៤ សហវ.មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ។
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ។
- បានឃើញសារាចរណែនាំលេខ 00២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល។
- យោងប្រកាសអន្តរក្រសួងលេខ..................ប្រក.បទ.សហវ.ចមព ចុះថ្ងៃទី.........ខែ.............ឆ្នាំ ២០០៦ ស្តីពី អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ។

## ស ម្រេ ច

**ប្រការ ១:** ត្រូវបានអនុញ្ញាតឱ្យនាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័តនិងទំនាក់ទំនងអន្តរជាតិ ដកប្រាក់ឧបត្ថម សម្រាប់ក្រុមការងារត្រួតពិនិត្យនិងការងារគ្រប់គ្រងជាប្រចាំ នៃប្រាក់ចំណូលដែលបានមកពីថ្លៃអាជ្ញាប័ណ្ណ សេវាបញ្ញើឆាប់រហ័សអន្តរជាតិ និងប្រាក់ចំណូលដែលបានមកពីការផាកពិន័យ។

**ប្រការ ២:** ដើម្បីធានាឱ្យការគ្រប់គ្រង និងការផ្តល់អាជ្ញាប័ណ្ណ ដំណើរការទៅដោយប្រសិទ្ធិភាព ប្រាក់ចំណូលដែលបាន មកពីថ្លៃអាជ្ញាប័ណ្ណ និងការផាកពិន័យ ត្រូវបង់ចូលថវិកាជាតិ ចំនួន ១00% ក្នុងនោះ :

- ប្រាក់ចំណូលដែលបានមកពីថ្លៃអាជ្ញាប័ណ្ណ ចំនួន ៣0% សម្រាប់ឧបត្ថមក្រុមការងារ ត្រួតពិនិត្យនិងការងារគ្រប់គ្រង។
- ប្រាក់ចំណូលដែលបានមកពីការផាកពិន័យ ចំនួន ៥0% សម្រាប់ឧបត្ថមក្រុមការងារ ត្រួតពិនិត្យនិងការងារគ្រប់គ្រង។

**ប្រការ ៣:** អគ្គនាយកដ្ឋាន នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឪវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
  "ដើម្បីមុខការ"
- ឯកសារ- កាលប្បវត្តិ